វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

រាជរដ្ឋាភិបាលកម្ពុជា

អនុក្រឹត្យ/៧៣ អនក្រ.បក/០៤ វិច្ឆិកា ១៩៩៧/

# អនុក្រឹត្យ ស្តីពីសៀវភៅស្នាក់នៅ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ ជ.ស-រកត-០៨៩៧-១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៧

## សំរេច

មាត្រា១:

ត្រូវបានបង្កើតសៀវភៅស្នាក់នៅ ដូចមានគំរូចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២:

សៀវភៅស្នាក់នៅ ជាសៀវភៅសំរាប់ប្រើប្រាស់វិធានការនគរបាល ដើម្បីស្រង់ពតិមានអំពីចំនួនមនុស្សដែលស្នាក់នៅក្នុងគេហដ្ឋានទីមួយៗ ។ សៀវភៅនេះ មិនសំរាប់បញ្ជាក់អំពីញាតិភាព ឬសញ្ជាតិខ្មែរនៃមនុស្ស ដែលមានឈ្មោះចុះក្នុងបញ្ជីសៀវភៅនេះឡើយ ។

មាត្រា៣:

ជនគ្រប់រូបដែលជាអ្នកទទួលខុសត្រូវចម្បងនៃគេហដ្ឋានទីមួយៗ ទោះជាជននោះជាម្ចាស់ផ្ទះក្តី ឬជាអ្នកជួលក្តី មានកាតព្វកិច្ចចុះក្នុងសៀវភៅស្នាក់នៅ នូវឈ្មោះមនុស្សគ្រប់រូប ដែលរស់នៅជាប់លាប់ជាមួយខ្លួន ។

មាត្រា៤:

ការគ្រប់គ្រង និងការចុះឈ្មោះសៀវភៅស្នាក់នៅ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

មាត្រា៥:

បែបបទនៃការចុះឈ្មោះក្នុងសៀវភៅស្នាក់នៅ ត្រូវកំណត់ដោយប្រកាសក្រសួងមហាផ្ទៃ ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

មាត្រា៦:

អ្នកទទួលខុសត្រូវចម្បងណា ដែលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមមាត្រា ៣ នៃអនុក្រឹត្យនេះ ក្នុងរយៈពេលយ៉ាងយូរបីខែបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ត្រូវពិន័យជាប្រាក់ ៥០.០០០រ០០(ប្រាំម៉ឺនរៀល) និងតម្រូវអោយជននោះចុះឈ្មោះខ្លួន និងសមាជិកខ្លួនក្នុងសៀវភៅ ស្នាក់នៅ ចាប់ពីថ្ងៃដែលពិន័យជាប្រាក់ខាងលើនេះ។

មាត្រា៧:

អាជ្ញាធរមានសមត្ថកិច្ចណា ដែលអនុវត្តភារកិច្ចផ្ទុយពីបទបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

មាត្រា៨:

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៩:

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវ អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។